Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

## 2018 PUBLIC EXAMINATION

# Khmer

## Continuers Level

**Tuesday 23 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2018

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

1. What is the purpose of Kin Sona's speech? **2**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) Why does Sarath want to join his parents on their trip to Cambodia? **3**

(b) Describe the relationship between Sarath and his mother. Support your answer with evidence from the text. **4**

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) Why does Champey look different? **1**

(b) What caused Champey's mother-in-law and father-in-law to argue? **1**

(c) What are the reasons behind the different points of view held by Champey's mother-in-law and father-in-law? **4**

**Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 4**

4. Identify four features that make Capital Tours appealing to customers. **2**

ចូរបង្ហាញលក្ខណៈបួនយ៉ាងដែលធ្វើអោយអតិថិជនមានចំណាប់អារម្មណ៍នឹងកាពីតាល់ធួរ។

________________________________________________________

________________________________________________________

________________________________________________________

________________________________________________________

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. (a) How do the speakers show respect for each other? Provide examples from the text to support your answer. **3**

តើអ្នកនិយាយទាំងពីរនាក់បង្ហាញការគោរពគ្នាទៅវិញទៅមកយ៉ាងណាខ្លះ? ចូរផ្តល់ឧទាហរណ៍ពីអត្ថបទដើម្បីគាំទ្រចម្លើយរបស់អ្នក។

(b) How did Mr Chhom Ponleu come to be an Ayay singer? **2**

តើលោកឆុំ ពន្លឺបានក្លាយទៅជាអ្នកច្រៀងអាយ៉ៃដោយរបៀបណា?

(c) What qualities does someone need to possess to be a good Ayay singer? **3**

តើគុណភាពអ្វីខ្លះដែលអ្នកណាម្នាក់ត្រូវមានដើម្បីក្លាយទៅជាអ្នកច្រៀងអាយ៉ៃពូកែម្នាក់?

Marks | You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) How has Sary's height impacted on his sporting life? **3**
Provide examples from the text to support your answer.
តើកម្ពស់របស់សារីធ្វើអោយប៉ះពាល់យ៉ាងណាខ្លះទៅលើជីវភាពកីឡារបស់វា?

___

___

___

___

___

___

(b) Why does Bopha state, 'That's a pity, little fellow'? **2**
ហេតុអ្វីបានជាបុប្ផានិយាយថា'គួរអោយស្រណោះដល់ក្មេងកន្លឿនេះណាស់'?

___

___

___

___

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2018**

**Section 1: Listening and Responding**

## PART A

***Text 1***

អស់លោកលោកស្រីជាទីមេត្រី! ខ្ញុំបាទឈ្មោះគិន សូណា ជាលេខាធិការនៃសមាគមខ្មែរ។ សូមស្វាគមន៍លោកអ្នកដល់មហាសន្និបាតប្រចាំឆ្នាំនេះ។ តាងនាមគណៈកម្មការរបស់សមាគម ខ្ញុំបាទសូមថ្លែងអំណរគុណជាខ្លាំងដល់វត្តមានរបស់អស់លោកលោកស្រីនៅវេលាល្ងាចនេះ។ ខ្ញុំមានសេចក្តីរីករាយជាអនេកដែលបានឃើញថាមានមនុស្សច្រើនជាងឆ្នាំមុនមកចូលរួមប្រជុំ ដើម្បីធ្វើការជ្រើសរើសគណៈកម្មការថ្មី។ សូមបញ្ជាក់ថាក្នុងពេលប្រជុំលោកអ្នកអាចទៅយកអាហារនិងភេសជ្ជៈដោយខ្លួនឯងមកទទួលទានបាន។ ឥឡូវណេះខ្ញុំបាទសូមអញ្ជើញលោកប្រធានមកធ្វើរបាយការណ៍។ សូមស្វាគមន៍លោក ទូន វិចិត្រ ប្រធានសមាគមខ្មែរ។ (*Clap, clap, clap…*)

***Text 2***

ម	សារ៉ាត់ ម៉ាក់និងប៉ាចង់នាំឯងទៅលេងប្រទេសកម្ពុជាជាមួយយើងបើឯងប្រឡងជាប់ឆ្នាំនេះ។ ឯងចង់ទៅទេ?

ស	បាទ ខ្ញុំចង់ដែរ។

ម	ល្អ ឯងធំហើយណ៎ា ហើយមិនទាន់មានមិត្តស្រីនៅឡើយ។ ម៉ាក់អាចណែនាំឯងអោយស្គាល់នារីមួយចំនួននៅទីនោះ។ ឯងអាចពេញចិត្តនារីណាម្នាក់ក៏ថាបាន។

ស	ទេ ទេ ម៉ាក់ ខ្ញុំប្តូរចិត្តវិញហើយ។

ម	ហាស់ ហា! ម៉ាក់និយាយលេងទេ។ តាមពិតម៉ាក់ចង់អោយឯងទៅស្គាល់មាមីង បងប្អូនជីដូនមួយ និងជាពិសេសជីដូនជីតារបស់ឯងទេ។

ស	មែនហើយម៉ាក់ ខ្ញុំមិនដែលស្គាល់គាត់ទាំងនោះទេព្រោះគ្រួសារយើងបានចាកចេញពីប្រទេសកម្ពុជាតាំងពីខ្ញុំនៅតូចម្ល៉េះ។ ខ្ញុំចង់ជួបគាត់ទាំងអស់គ្នា និងទៅមើលកន្លែងកំណើតខ្ញុំណាស់ ហើយចង់ដើរលេងកំសាន្តកន្លែងនានា ព្រមទាំងទៅមើលប្រាសាទល្អៗដែរ។ ប៉ុន្តែម៉ាក់ ខ្ញុំនិយាយខ្មែរមិនសូវច្បាស់ទេណ៎ា។

ម	កុំបារម្ភអី ខ្មែរយើងជាសាសន៍រាក់ទាក់ ហើយចូលចិត្តសប្បាយ។ ឯងនឹងមិនអីទេ។

ស	ខ្ញុំត្រូវបង់ថ្លៃយន្តហោះ ម្ហូបអាហារ និងថ្លៃស្នាក់នៅប៉ុន្មានទៅម៉ាក់?

ម	ឯងកុំភ័យ ម៉ាក់ប៉ាចេញអោយឯងទាំងអស់អោយតែឯងទៅ។

ស	ម៉ាក់ ដឹងថាហេតុអីបានជាខ្ញុំមិនសូវចង់ទៅជាមួយម៉ាក់ប៉ាទេ?

ម	ហេតុអី?

ស	ព្រោះខ្ញុំចង់អោយម៉ាក់និងប៉ារ៉ូមុិនទិចជាមួយគ្នាហ្នឹងណ៎ា! ហាស់ ហា!

ម	វាអស់រ៉ូមុិនទិចអីទៀតហើយ។ អេ! បើមិនចង់ទៅទេ ម៉ាក់នឹងមានលុយច្រើនសម្រាប់ចាយអីផ្សេងវិញណ៎ា ហាស់ ហា!។

***Text 3***

| | |
|---|---|
| ចាន់ថន | សួស្តីចំប៉ី សុខសប្បាយទេ។ ខ្ញុំខានឃើញឯងយូរហើយ។ |
| ចំប៉ី | សុខសប្បាយទេ អរគុណ។ ខ្ញុំផ្លាស់ទៅនៅ Perth ជាមួយប្តីខ្ញុំក្រោយពេលរៀបការរួច។ |
| ចាន់ថន | ឯងស្អាតណាស់ ប៉ុន្តែដូចជាប្លែកម៉េចមិនដឹងទេ។ |
| ចំប៉ី | មែនហើយ ទាយទៅមើល ខ្ញុំមានគ៌ភ២ខែហើយណ៎ា! |
| ចាន់ថន | មែនអ្វី? ជួយអបអរផង! ឯងទាំងពីរនាក់មិនដឹងជាលោតកញ្ឆ្រញយ៉ាងណាទេ។ |
| ចំប៉ី | មែនហើយ ជាពិសេសម៉ាក់ប៉ាខ្ញុំ។ |
| ចាន់ថន | ល្អមែនទែន! ឯងដឹងថាជាកូនប្រុសឬស្រីហើយឬនៅ? |
| ចំប៉ី | នៅទេ។ ប្តីខ្ញុំនិងខ្ញុំមិនសូវខ្វាយខ្វល់រឿងហ្នឹងទេ។ ប៉ុន្តែប៉ាក្មេកខ្ញុំឯណោះទេដែលចង់បានចៅប្រុសមុនចៅស្រី ឯម៉ាក់ក្មេកខ្ញុំវិញចង់បានចៅស្រីមុនចៅប្រុស។ គាត់ទាំងពីរនាក់ជជែកគ្នាពេញមួយយប់ក្នុងរឿងហ្នឹង។ |
| ចាន់ថន | ហេតុអីបានជាគាត់គិតអញ្ចឹង? |
| ចំប៉ី | ប៉ាក្មេកខ្ញុំគាត់មានជាប់សាច់ឈាមចិន។ គាត់យល់ថា វាជាការសំខាន់ដែលគ្រួសារត្រូវតែបន្តត្រកូលពីមួយជំនាន់ទៅមួយជំនាន់ទៀត ហើយមានតែកូនប្រុសទេដែលអាចបន្តត្រកូលបាន។ |
| ចាន់ថន | តែប៉ុណ្ណឹងទេអ្វី? |
| ចំប៉ី | ទេ គាត់ថែមទៀតថា កូនប្រុសមិនសូវបារម្ភក្នុងការថែរក្សាដូចកូនស្រីទេ។ ប៉ុន្តែម៉ាក់ក្មេកខ្ញុំគិតផ្ទុយពីនេះទៅវិញ។ គាត់យល់ថាកូនស្រីអាចមើលថែប្អូនប្រុសរបស់វាបានល្អពេលវារស់នៅជាមួយគ្នា ហើយប្អូនប្រុសនឹងមានចរឹតទន់ភ្លន់ពេលវាធំឡើង។ |
| ចាន់ថន | ការដែលសំខាន់នោះអោយតែគាត់ស្រឡាញ់ចៅៗស្មើគ្នា វាមិនទាស់អីនឹងអ្នកណាកើតមុនទេ។ |

**PART B**

***Text 4***

កាពីតាល់ធួរជាក្រុមហ៊ុនដឹកនាំទេសចរដែលទើបនឹងបើកការិយាល័យទីមួយរបស់គេនៅភ្នំពេញ។ បុគ្គលិករបស់យើងដែលមានឯកទេស និងរាក់ទាក់បំផុត កំពុងរង់ចាំផ្តល់សេវាដ៏ល្អដាច់គេនិងផ្តល់យោបល់ផ្នែកដើរលេងកំសាន្តតាមតម្រូវការរបស់លោកអ្នក។

មិនថាការដើរលេងកំសាន្តជាក្រុមៗ ឬការដើរលេងកំសាន្តជាលក្ខណៈផ្ទាល់ខ្លួនទេ ក្រុមហ៊ុនយើងខ្ញុំអាចទទួលបានទាំងអស់។ យើងមានបុគ្គលិកដែលចេះនិយាយភាសាច្រើនសាសន៍ដើម្បីជួយសម្រួលដល់សេចក្តីត្រូវការក្នុងដំណើរកំសាន្តរបស់លោកអ្នក។ តម្លៃឈ្នួលសមរម្យនិងសុវត្ថិភាពរបស់លោកអ្នកជាគោលដៅធំចំបងរបស់យើង។

សូមអញ្ជើញលោកអ្នកឆែកវ៉ិបសាយរបស់យើង ដើម្បីបានពត៌មានអំពីតម្លៃពិសេសសម្រាប់បើកហាងថ្មីរបស់យើង។

*Text 5*

អ្នកសំភាស អស់លោកលោកស្រីជាទីមេត្រី ក្នុងប្រូក្រាមយប់នេះ យើងមានសំណាងល្អបាន ភ្ញៀវកិត្តិយសពិសេសរបស់យើងម្នាក់ដែលជាអ្នកច្រៀងអាយ៉ៃដ៏ឆ្នើមម្នាក់គឺ លោកតាឆុំ ពន្លឺ។ ជំរាបសួរលោកតា។

ពន្លឺ បាទ ជំរាបសួរក្មួយ។

អ្នកសំភាស តើលោកតាបានចាប់ផ្តើមប្រកបអាជីពជាអ្នកច្រៀងអាយ៉ៃតាំងពីពេលណាមក?

ពន្លឺ បាទ ខ្ញុំខ្វាក់ភ្នែកតាំងតែពីខ្ញុំអាយុ៧ឆ្នាំម្ល៉េះដោយសារជំងឺអុតតូច។ ភាពពិការនេះធ្វើ អោយខ្ញុំមានចំណាប់អារម្មណ៍នឹងរបៀបច្រៀងអាយ៉ៃ។ សំណាងល្អ ខ្ញុំមានមាខ្ញុំ ម្នាក់ដែលជាគ្រូបង្រៀនចំរៀងយីកេ បង្ហាត់ខ្ញុំអោយចេះច្រៀងអាយ៉ៃកាលពីខ្ញុំ អាយុ១០ឆ្នាំ។

អ្នកសំភាស អ្វីដែលធ្វើអោយលោកតានិងដៃគូ ក្លាយទៅជាក្រុមច្រៀងអាយ៉ៃដ៏ល្អដាច់គេនៅ ប្រទេសកម្ពុជា?

ពន្លឺ អាយ៉ៃជាសិល្បៈប្រភេទពិសេសមួយរបស់ខ្មែរ។ អ្នកច្រៀងកំប្លែងស្រីនិងប្រុសពីរ នាក់ ច្រៀងសួរគ្នាទៅវិញទៅមកអំពីប្រធានបទមួយចំនួន ដោយប្រើពាក្យជូនៗគ្នា។ របៀបនេះវាតម្រូវអោយអ្នកច្រៀងម្នាក់ៗចេះពាក្យជូនគ្នាច្រើន ចេះកំណាព្យ ច្បាស់លាស់ និងត្រូវចេះកំប្លែងផង។ ការពិបាកម្យ៉ាងទៀតនោះគឺអ្នកច្រៀងអាយ៉ៃ ត្រូវមានទេពកោសល្យខាងនឹកឃើញពាក្យជូនៗគ្នាភ្លាមៗដើម្បីច្រៀងតបទៅដៃគូ របស់គេវិញ។ អ្នកច្រៀងត្រូវមានអំណត់ធ្មត់ខ្ពស់ និងត្រូវហាត់ហ្វឹកហ្វឺនច្រើន ណាស់។ ខ្ញុំមានលក្ខណៈទាំងអស់នេះពីលើសំឡេងដ៏ពិរោះរបស់ខ្ញុំ។

អ្នកសំភាស តើការមានដៃគូច្រៀងល្អវាសំខាន់យ៉ាងម៉េចទៅ?

ពន្លឺ បាទ ដៃគូច្រៀងល្អវាសំខាន់ណាស់។ ខ្ញុំសំណាងណាស់ដែលមានដៃគូដ៏ល្អ ម្នាក់។ អញ្ចឹងហើយបានជាក្រុមអាយ៉ៃរបស់ខ្ញុំជាក្រុមអាយ៉ៃល្អដាច់គេនៅប្រទេស កម្ពុជា។

អ្នកសំភាស អរគុណលោកតា ហើយសូមអោយមានសំណាងល្អក្នុងអាជីពរបស់លោកតា។

*Text 6*

បុប្ផា សារី ឯងចូលចិត្តកីឡាទេ?

សារី អ៎ូហ ចូលចិត្តណាស់កាលនៅស្រុកខ្មែរ។

បុប្ផា ខ្ញុំមិនដែលឃើញឯងលេងកីឡាអីសោះនៅអូស្ត្រាលីនេះ។

សារី កាលខ្ញុំនៅពីក្មេងប្រហែល១១ឆ្នាំ ខ្ញុំចូលចិត្តលេងលោតកម្ពស់ខ្លាំងណាស់។ ខ្ញុំតែងឆ្លៀតយកពេលគេងថ្ងៃត្រង់ទៅហាត់លោតកម្ពស់តែម្នាក់ឯងនៅទីធ្លាសាលាវិទ្យាល័យជាប់របងផ្ទះខ្ញុំ។

បុប្ផា ឯងប្រាកដជាពូកែខាងលោតកម្ពស់ហើយមើលទៅ?

សារី ត្រូវហើយ ខ្ញុំជាសិស្សពូកែម្នាក់ខាងលោតកម្ពស់នៅវិទ្យាល័យខ្ញុំ ពីព្រោះខ្ញុំអាចលោតបានខ្ពស់ជាងកម្ពស់ខ្ញុំ។ ប៉ុន្តែឥឡូវណោះខ្ញុំទាបពេក ដូច្នេះខ្ញុំមិនអាចប្រកួតជាមួយនឹងគេខ្ពស់ៗបានទេ។

បុប្ផា ឯងចូលចិត្តកីឡាអីទៀតដែរ?

សារី កីឡាបាល់ទាត់ជាកីឡាមួយទៀតដែលខ្ញុំចូលចិត្ត។ កាលពីដើមខ្ញុំតែងតែដើរម្នាក់ឯងយ៉ាងឆ្ងាយទៅមើលការប្រកួតកីឡាបាល់ទាត់។ ខ្ញុំធ្លាប់លេងបាល់ទាត់ជាអ្នកចាំទី។ ដដែល ដោយសារខ្ញុំទាបពេក ខ្ញុំមិនអាចធ្វើជាអ្នកចាំទីល្អបានទេ។ នៅប្រទេសអូស្ត្រាលីខ្ញុំគ្រាន់តែមើលគេលេងប៉ុណ្ណោះ។

បុប្ផា ឯងចូលចិត្តលេងអីទៀតទេ?

សារី ធ្លាប់លេងគ្គីតា។

បុប្ផា ហ្នឹងវាមិនត្រូវការកម្ពស់ទេមែនទេ? ឯងប្រាកដជាពូកែលេងហើយ។

សារី ត្រូវហើយ ប៉ុន្តែនៅស្រុកខ្មែរសិស្សមិនមានលទ្ធភាពជ្រើសរើសរៀនលេងភ្លេងនៅសាលាទេ។ ខ្ញុំយកប្រាក់សន្សំខ្ញុំទៅបង់ថ្លៃឈ្នួលរៀនលេងគ្គីតានៅភ្នំពេញ។ ខ្ញុំគ្មានលទ្ធភាពដដែលនេះទៀតទេ ពេលឪពុកម្តាយខ្ញុំបានផ្លាស់ទៅរស់នៅខេត្តតាកែវ។

បុប្ផា គួរអោយស្រណោះដល់ក្មេងកន្លឿនេះណាស់!

Student/Registration Number | | | | | | | | | | | Centre Number | | | | | |

## 2018 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2018*

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

This text cannot be reproduced here for copyright reasons.

QUESTIONS

**Marks**

(a) What impact is tourism having on Angkor Wat and the surrounding area, according to the text? **2**

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

(b) What actions are the government and the Cambodian Director of Tourism considering, according to the text? **2**

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

8. Read the text and then answer in ENGLISH the question that follows.

## ស្ត្រីជំនាន់ថ្មីនៅប្រទេសកម្ពុជា

ក្នុងប្រទេសមួយដែលទំនៀមទំលាប់បុរាណធ្លាប់បានគ្របដណ្តប់ជាយូរលង់ទៅលើការរស់នៅរបស់មនុស្ស មុខងាររបស់ស្ត្រីកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងន័យល្អ។

កាលពីជំនាន់ដើមនៅប្រទេសកម្ពុជា ចំពោះក្មេងប្រុសបីនាក់មានស្រីតែម្នាក់ប៉ុណ្ណោះដែលបានទៅសិក្សានៅមហាវិទ្យាល័យ។ កាលណោះគេគិតថា កាលណាស្ត្រីបានទទួលការសិក្សាខ្ពស់ពេក វានឹងធ្វើអោយស្ត្រីនោះមានការពិបាកក្នុងការរកគូស្រករ ហើយមានគ្រួសារក្រីក្រច្រើនណាស់ដែលមិនមានលទ្ធភាពផ្គត់ផ្គង់កូនស្រីរបស់ខ្លួននៅសាលា។ ក្មេងស្រីជាច្រើននាក់នៅប្រទេសកម្ពុជាត្រូវបញ្ឈប់ការសិក្សាដើម្បីជួយធ្វើការមាតាបិតា ឯខ្លះទៀតត្រូវរហ័សមានគូស្រករ។

ទោះជាយ៉ាងណាក្តី ពេលវេលាបានផ្លាស់ប្តូរយ៉ាងលឿន។ ក្នុងវិស័យការងារ ឥឡូវណេះស្ត្រីហ៊ានខ្ចីប្រាក់ធនាគារដើម្បីយកមកធ្វើជាដើមទុនក្នុងការបង្កើតមុខរបរផ្ទាល់ខ្លួន ដើម្បីបង្កើនប្រាក់ចំណូលនិងកាន់តែមានថវិកាគ្រប់គ្រាន់សម្រាប់ខ្លួនឯង។

ស្ត្រីទាំងនោះមិនត្រឹមតែអាចផ្គត់ផ្គង់ដល់ការហូបចុកនៃគ្រួសាររបស់ខ្លួនទេ គេថែមទាំងអាចយកប្រាក់ចំណេញទាំងនោះសម្រាប់ផ្តល់ថវិកាដល់គ្រួសាររបស់គេ និងអាចមានលទ្ធភាពជួយកូនរបស់គេទាំងអស់បាននៅរៀនសាលាយូរថែមទៀតផង។

ដូច្នេះកាលណាក្មេងខ្មែរទាំងអស់អាចបានទទួលការអប់រំគ្រប់ៗគ្នា ជាពិសេសស្ត្រីដែលមានចំណេះវិជ្ជានឹងបានសម្រេចគោលបំណងពេញលេញរបស់គេ។ នេះជាការផ្លាស់ប្តូរដ៏អស្ចារ្យមួយ!

QUESTIONS

**Marks**

(a) Explain the title, 'New generation of women in Cambodia', in the context of the text. **3**

(b) What techniques are used by the authors of Text 7 and Text 8 to support their points of view? Justify your answer with examples from the text. **3**

**Part B** (Question 9)
(15 marks)

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

9. Read the text and then answer the question in approximately 150 words in KHMER.

CambodiAID ត្រូវការជំនួយអ្នក

CambodiAID គឺជាអង្គការមនុស្សធម៌ថ្មីមួយដែលមានទីតាំងនៅភ្នំពេញ ផ្ដល់កិច្ចបម្រើខាងផ្នែកសុខាភិបាល។ កិច្ចបម្រើទាំងនោះរួមមានផ្ដល់ទឹកស្អាត ចាក់ថ្នាំបង្ការរោគ អប់រំផ្នែកសុខភាព និងផ្ដល់អ្វីៗច្រើនទៀតដែលជាតម្រូវការចាំបាច់របស់ជនក្រីក្រទាំងឡាយរស់នៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ជាពិសេសតំបន់ណាដែលការទទួលកិច្ចបម្រើពីមន្ទីរពេទ្យរដ្ឋមានការពិបាកខ្លាំងបំផុត។ យើងខ្ញុំត្រូវការជំនួយរបស់អ្នកដើម្បីអោយយើងបានសម្រេចគោលបំណងរបស់យើង។

មានមធ្យោបាយច្រើនណាស់ដែលអ្នកអាចជួយយើងបាន។

- រិះរកមធ្យោបាយផ្សាយអំពីអង្គការយើងក្នុងសហគមន៍របស់លោកអ្នក។
- ជួយលើកទឹកចិត្តដល់អ្នកដទៃអោយមកចូលបម្រើក្នុងអង្គការយើង។
- ផ្ដល់ពត៌មានមកយើងអំពីតំបន់ដាច់ស្រយាលនានានៅប្រទេសកម្ពុជាដែលអស់សង្ឃឹមនឹងបានទទួលជំនួយ។
- រៀបចំធ្វើការអង្គាសប្រាក់សម្រាប់ផ្ដល់បៀវត្សដល់ភ្នាក់ងារសុខភាពខ្មែរ។
- ស្ម័គ្រចិត្តធ្វើការជាមួយយើងជាអ្នកបកប្រែភាសាសរសេរឬផ្ទាល់មាត់ ឬជាអ្នកទទួលទូរស័ព្ទក្នុងការិយាល័យយើងនៅប្រទេសកម្ពុជា។

ពត៌មានបន្ថែម សូមលោកអ្នកទាក់ទងមកលោក ចាប លឹម តាមរយៈអ៊ីមែល
Chap.volunteer@cambodiaid.org.kh

QUESTION

You have read this advertisement in your community newspaper and decide to respond immediately. Write an email to CambodiAID explaining how you can help, and seeking any further information that you need from this organisation.

អ្នកបានអានក្រដាសផ្សាយដំណឹងនេះនៅក្នុងសារពត៌មានតំបន់របស់អ្នក ហើយសម្រេចចិត្តថា នឹងឆ្លើយតបវិញមួយរំពេច។ ចូរអ្នកសរសេរអ៊ីមែលមួយដើម្បីពន្យល់ទៅអង្គការ CambodiAID ថាតើអ្នកអាចជួយដោយរបៀបណា និងសាកសួរពត៌មានបន្ថែមទៀតដែលអ្នកត្រូវការពីអង្គការនេះ។

---

You may make notes in this space.



PLEASE TURN OVER

This page is intentionally blank

Question 9



PLEASE TURN OVER

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2018 PUBLIC EXAMINATION

# Khmer

## Continuers Level

### Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2018*

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. You have been asked to coordinate your Khmer community association's participation in the Australia Day parade in your nearest capital city.

    Write a talk to present to the association members, persuading them to join in the activities of the day and outlining what they will have to do.

    អ្នកត្រូវបានគេចាត់តាំងអោយចាត់ចែងដឹកនាំការចូលរួមដង្ហែ *អូស្ត្រាលីយ៉ាដេ* របស់សមាគមខ្មែរ អ្នកនៅក្នុងរដ្ឋធានីជិតលំនៅរបស់អ្នក។

    ចូរអ្នកសរសេរអត្ថបទនិយាយមួយ សម្រាប់ថ្លែងទៅកាន់សមាជិកសមាគម ដើម្បីបញ្ចុះបញ្ចូលគេអោយមកចូលរួមក្នុងសកម្មភាពថ្ងៃនេះ ហើយនិងបញ្ជាក់អំពីកិច្ចការទាំងឡាយដែលគេត្រូវធ្វើ។

11. You have been living in Australia for a number of years now, and have visited many places in Australia.

    Write a review for an online travel blog evaluating your experiences.

    អ្នកបានមករស់នៅប្រទេសអូស្ត្រាលីចំនួនច្រើនឆ្នាំមកហើយ ហើយអ្នកធ្លាប់បានទៅដើរលេងកំសាន្តជាច្រើនកន្លែងនៅប្រទេសអូស្ត្រាលី។

    ចូរអ្នកសរសេរអត្ថបទវាយតម្លៃមួយសម្រាប់ចុះផ្សាយក្នុងអនឡាញប្លកដើរលេងកំសាន្តមួយដោយធ្វើការវាយតម្លៃអំពីបទពិសោធន៍របស់អ្នក។

12. After your graduation, your grandparents want you to come home and work in Cambodia.

    Write a letter persuading them why you want to live and work in Australia.

    ក្រោយពីបានទទួលសញ្ញាប័ត្រសិក្សារួច ជីដូនជីតារបស់អ្នកចង់អោយអ្នកត្រឡប់មកផ្ទះ និងធ្វើការនៅប្រទេសកម្ពុជាវិញ។

    ចូរអ្នកសរសេរសំបុត្រមួយផ្ញើទៅជូនជីដូនជីតារបស់អ្នកបញ្ចុះបញ្ចូលគាត់អំពីហេតុអ្វីបានជាអ្នកចង់រស់នៅ និងធ្វើការនៅប្រទេសអូស្ត្រាលី។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.



PLEASE TURN OVER

This page is intentionally blank

Question Number:

**End of Section 3**